ធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ និងក្រុមហ៊ុនអគ្គិសនីកម្ពុជា មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៨ តទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★

## ៣-បទបញ្ជា

## បទបញ្ជា លេខ ២៥ បប

## របស់រាជរដ្ឋាភិបាល

***

តាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានបញ្ជាក់ថា នៅរដូវទឹក ចំឡើង ឆ្នាំនេះ សកម្មភាពជនល្មើសបាន និងកំពុងត្រៀមឧបករណ៍សំភារៈដាយចាប់កូនត្រីព្រាម្សៅ និងជនល្មើសខ្លះទៀតបានដាក់ដាយចាប់កូនត្រីព្រាម្សៅហើយផុលផុសតាមបណ្ដោយចំណោត មួយចំនួនធំនៅក្នុងខេត្តកំពង់ចាម កណ្ដាល ព្រៃវែង កំពង់ឆ្នាំង និងរាជធានីភ្នំពេញ ។

ដើម្បីរាំងខ្ទប់បទល្មើសនេសាទខាងលើនេះអោយមានប្រសិទ្ធភាព រាជរដ្ឋាភិបាលដាក់ចេញបទបញ្ជា ដូចតទៅ ៖

១-ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ត្រូវដកកម្លាំងប្រដាប់អាវុធទាំងអស់ដែលពាក់ព័ន្ធចេញពីចំណុចបទល្មើសដាក់ដាយចាប់កូនត្រីព្រាម្សៅទាំងអស់ជាបន្ទាន់ ។

២-អភិបាលខេត្តកំពង់ចាម កណ្ដាល ព្រៃវែង កំពង់ឆ្នាំង និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវណែនាំកងកម្លាំងប្រដាប់អាវុធនៅក្នុងខេត្ត-ក្រុងសាមីទាំងអស់ដែលពាក់ព័ន្ធអោយដកចេញពីចំណុចបទល្មើសដាក់ដាយចាប់កូនត្រីព្រាជាបន្ទាន់ ព្រមទាំងណែនាំស្រុក ខណ្ឌ - ឃុំ - សង្កាត់ អោយអប់រំប្រជាជនដែលបាននិងកំពុងប្រព្រឹត្តបទល្មើស អោយបញ្ឈប់សកម្មភាពជាបន្ទាន់ ។

៣-ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ អគ្គនាយកដ្ឋាននគរបាលជាតិត្រូវត្រៀមសហការជាមួយសមត្ថកិច្ចជលផលចូលរួមបង្ក្រាបបទល្មើសពេលសមត្ថកិច្ចជលផលស្នើសុំ ។

៤-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវជំរុញអោយសមត្ថកិច្ចជលផលគ្រប់លំដាប់ថ្នាក់ចុះត្រួតពិនិត្យ និង បង្ក្រាបបទល្មើសនេសាទគ្រប់ប្រភេទ ពិសេសបទល្មើសដាក់ដាយចាប់កូនត្រីព្រាអោយមានប្រសិទ្ធភាព ។ ក្នុងករណីចាំបាច់សមត្ថកិច្ចជលផលអាចស្នើសុំកងកម្លាំងប្រដាប់អាវុធ និងរដ្ឋអំណាចមូលដ្ឋានជួយជាកម្លាំង ។

មន្ត្រីបានលើកឡើងនេះ ក្រសួង- ខេត្ត- ក្រុង ដែលពាក់ព័ន្ធខាងលើ ត្រូវទទួលអនុវត្តដោយមានការ សហការគ្នាយ៉ាងត្រឹមត្រូវនិងអោយបានសំរេចលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

★★★

# III- ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៨

### ប្រកាសលេខ ៤៧៨ ប្រក.ឧក

***

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេច នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ២៣១១/៩៧ ក.អ.ក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧ របស់ក្រុម ប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-បានឃើញលិខិតលេខ ២៣៨៦ ធត.សរ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់សាលាក្រុង ភ្នំពេញ ស្តីពីការអនុញ្ញាតបើកទីតាំងរោងចក្រកាត់ដេរ

-យោងពាក្យស្នើរបស់ក្រុមហ៊ុន ឆេរី ហ្វេស្សិន ម៉េញូហ្វាក់ឆឺរីង ( ខេមបូឌា ) ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៨ ។

### សំរេច

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន ឆេរី ហ្វេស្សិន ម៉េញូហ្វាក់ឆឺរីង ( ខេមបូឌា ) ( CHERRY FASHION MANUFACTU RING ( CAMBODIA ) LTD. ) តំណាងដោយលោក TSUI WING KEI RICK សញ្ជាតិ អង់គ្លេស ភេទ ប្រុស អាយុ ៥១ ឆ្នាំ អាសយដ្ឋាន 32A, TOWER5, DYNASTY COURT23, OLD PEAK ROAD, HONG KONG កាន់លិខិតឆ្លងដែនលេខ 018580939